ព្រះរាជាណាចក្រកម្ពុជា
ជាតិ  សាសនា  ព្រះមហាក្សត្រ

អគ្គនាយកដ្ឋានពន្ធដារ
នៃក្រសួងសេដ្ឋកិច្ច  និង  ហិរញ្ញវត្ថុ
លេខ.......១៧៤២១.....អពដ

រាជធានីភ្នំពេញ, ថ្ងៃទី ០៤  ខែ ១០  ឆ្នាំ២០១៣

# សេចក្តីជូនដំណឹង
## ស្តីពី
## ការពន្យារពេលបង់ពន្ធលើអចលនទ្រព្យ សម្រាប់ឆ្នាំ២០១៣

អគ្គនាយកដ្ឋានពន្ធដារ  មានកិត្តិយសសូមជម្រាបជូនឯកឧត្តម  លោកជំទាវ  លោកឧកញ៉ា  លោក-លោកស្រី  ដែលជាម្ចាស់អចលនទ្រព្យទាំងអស់  មេត្តាជ្រាបថា  ក្នុងអំឡុងពេលជិតបញ្ចប់ការប្រមូលពន្ធលើអចលនទ្រព្យនាថ្ងៃទី៣០ ខែកញ្ញា កន្លងមកនេះ ឃើញថានៅមានម្ចាស់អចលនទ្រព្យ ជាច្រើននៅបាននិងកំពុងមមាញឹកមកប្រកាសបង់ពន្ធនៅតាមបណ្តាសាខាពន្ធដារខេត្ត-ខណ្ឌ  ជាហេតុ  ធ្វើឱ្យការផ្តល់សេវាជូនអ្នកជាប់ពន្ធមិនបានទាន់ពេលវេលា ។

ដូចនេះ  អគ្គនាយកដ្ឋានពន្ធដារសម្រេចពន្យារពេលប្រមូលពន្ធលើអចលនទ្រព្យ  រហូតដល់ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៣ បន្តទៀត ។

ដើម្បីផ្តល់លទ្ធភាពកាន់តែងាយស្រួលដល់ម្ចាស់អចលនទ្រព្យ  អគ្គនាយកដ្ឋានពន្ធដារបានរៀបចំចាត់ចែងផ្តល់សេវាប្រមូលពន្ធនៅថ្ងៃសៅរ៍-អាទិត្យ បន្ថែមទៀត ។

អគ្គនាយកដ្ឋានពន្ធដារ  មានក្តីសង្ឃឹមយ៉ាងមុតមាំថា  នៅក្នុងអំឡុងពេលពន្យារនេះ  ឯកឧត្តម  លោកជំទាវ  លោកឧកញ៉ា  លោក-លោកស្រី  ដែលជាម្ចាស់អចលនទ្រព្យទាំងអស់  នឹងរួសរាន់មកប្រកាសបង់ពន្ធបានទាន់ពេលវេលា និងចប់សព្វគ្រប់ត្រឹមថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៣ ខាងមុខនេះ ជាកំណត់ ។

ប្រតិភូរាជរដ្ឋាភិបាល
ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ

គង់ វិបុល